**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

សំណុំរឿង ព្រហ្មទណ្ឌ

លេខ: ៣៤០/០៨-៧-២០០០

សាលដីកាលេខ ១០០

ចុះថ្ងៃទី ០៦-៤-២០០១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី *៣០* ខែ *មីនា* ឆ្នាំ*២០០១* ដោយមានសមាសភាព ដូចតទៅ :

<u>ក្រុមប្រឹក្សាជំនុំជំរះ</u>

- លោក ច ន ប្រធាន
- លោក សរ សផ ចៅក្រមប្រឹក្សា
- លោក ស សរ ចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

-លោក គ ស ជាអយ្យការ

<u>ក្រឡាបញ្ជីសវនាការ</u>

-លោក ហ គរ ជាក្រឡាបញ្ជី

ដើម្បីជំនុំជំរះឡើងវិញតាមអំណាចសាលដីការបស់តុលាការកំពូល លេខ *១៩* ចុះថ្ងៃទី *០៥* ខែ *មិថុនា* ឆ្នាំ *២០០០* នូវរឿងព្រហ្មទណ្ឌលេខ*៣៤០* ចុះថ្ងៃទី *០៨* ខែ *កក្កដា* ឆ្នាំ *២០០០* របស់សាលាឧទ្ធរណ៍ :

*១-ជនជាប់ចោទឈ្មោះ រ ស ហៅ "ជ " ភេទ ប្រុស ជាតិ ខ្មែរ អាយុ ៣០ឆ្នាំ មុខរបរ កងរាជអាវុធហត្ថខេត្តរតនគិរី ទីលំនៅសព្វថ្ងៃ ភូមិ សន្សំកុសល សង្កាត់ បឹងទំពុន ខ័ណ្ឌ មានជ័យ ក្រុង ភ្នំពេញ ។ ឪពុកឈ្មោះ រ ជ "ស" ម្តាយឈ្មោះ ស ឡ "រ" ប្រពន្ធឈ្មោះ អ សថ មានកូន ៣ នាក់ (ចាប់ខ្លួនថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៩ ) ជាដើមបណ្តឹងឧទ្ធរណ៍ ។*



Scanned with CamScanner

Murd

ត្រូវចោទពីបទ "ធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន" ប្រព្រឹត្តនៅក្រុងភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-មេធាវី : ៩ សគ

២- ជនជាប់ចោទឈ្មោះ ង សរ ហៅ "ទ ស" ភេទ ប្រុស អាយុ ៩២ឆ្នាំ ជាតិ ខ្មែរ មុខរបរ នាំពាក់ទៅលក់នៅប្រទេសវៀតណាម ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤០០ ផ្លូវព្រះសីហនុ ក្រុមទី ១ សង្កាត់ ទួលស្វាយព្រៃទី ២ ខ័ណ្ឌ ចំការមន ក្រុង ភ្នំពេញ ។ ឪពុកឈ្មោះ គ "ស ម្តាយឈ្មោះ ន ឈ ប្រពន្ធឈ្មោះ ខ គះ មានកូន ៣នាក់ ទោសពីមុនគ្មាន ( នៅក្រៅឃុំ ) ។

-មេធាវី ខ សជ

៣- ជនជាប់ចោទឈ្មោះ ៩ សច ហៅ "ម សណ" ភេទ ប្រុស អាយុ ៣១ ឆ្នាំ ជាតិ ខ្មែរ មុខរបរ នគរបាលតម្រួតការពារ ទីលំនៅសព្វថ្ងៃក្រុមទី ១៥ សង្កាត់ ទន្លេបាសាក់ ខ័ណ្ឌ ចំការមន ក្រុង ភ្នំពេញ ឪពុកឈ្មោះ ម ន "វ" ម្តាយឈ្មោះ ស ន "វ" ប្រពន្ធឈ្មោះ ង សណ មានកូន ២នាក់ ( នៅក្នុងឃុំ ) ។

-មេធាវី ខ សជ

ត្រូវចោទពីបទសមគំនិតធ្វើមនុស្សឃាតដោយចេតនាគិតទុកមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៩ និង ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស មឡ ភេទ ស្រី អាយុ ៤០ឆ្នាំ ជាតិ ខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១៤៤ ផ្លូវមុន្នីរ៉េត សង្កាត់ ស្ទឹងមានជ័យ ខ័ណ្ឌ មានជ័យ ក្រុង ភ្នំពេញ ប្តីឈ្មោះ ម ម "ស" មានកូន ៧ នាក់ ។

<u>ឯរឿងហេតុមានដូចតទៅ</u>

តាមរបាយការណ៍របស់មន្ត្រីនគរបាលប៉ុស្តិ៍ទួលស្វាយព្រៃ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ បញ្ជាក់ថា កាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ វេលាម៉ោង ១៥ និង ៣០នាទី មានករណីបាញ់សម្លាប់មនុស្សខុសច្បាប់ កើតឡើងនៅពីមុខគ្លីនិកវិសាលសុខ ជនរងគ្រោះឈ្មោះ ម ម កងរាជអាវុធហត្ថ ដែលកំពុងឈរនិយាយទូរស័ព្ទ ស្រាប់តែមានជនល្មើសពីរនាក់ស្លៀកពាក់ស៊ីវិល ប្រដាប់ដោយអាវុធខ្លីមួយដើមម៉ាក K59 ជិះម៉ូតូមួយគ្រឿងម៉ាក Royal ពណ៌ក្រហមឧបត្ថា ហើយម្នាក់ចុះមកបាញ់ជនរងគ្រោះពីក្រោយចំនួន ០៤ គ្រាប់ បណ្តាលអោយជនរងគ្រោះដួលនៅនឹងកន្លែង ចំណែកជនល្មើសគេចខ្លួនបាត់ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៣ ( ច ) ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :



Scanned with CamScanner

១- ផ្តន្ទាទោសឈ្មោះ :

-រ ស ហៅ "ខ " ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ។

-ម មធ ដាក់ពន្ធនាគារកំណត់រយៈពេល ១០ ឆ្នាំ គិតពីថ្ងៃបានឃុំខ្លួនមក ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។

ពីបទធ្វើមនុស្សឃាតដោយគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ តាមបញ្ញត្តិមាត្រា ៣១ នៃបទបញ្ញត្តិអន្តរកាល ។

២- ផ្តន្ទាទោសលើឈ្មោះ :

-ចា សរ ហៅ "ខ ស" ដាក់ពន្ធនាគារកំណត់រយៈពេល ១៣ ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទសមគំនិតប្រព្រឹត្តបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ តាមមាត្រា ៦៩ និង មាត្រា ៣១ នៃបទបញ្ញត្តិអន្តរកាល ។

៣- អោយឈ្មោះ ខ សច ហៅ "ណា" បានរួចផុតពីការចោទប្រកាន់ទោស ពីបទសមគំនិត ប្រព្រឹត្តអំពើមនុស្សឃាតដោយគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។

៤- អោយឈ្មោះ ចា សរ ហៅ "ខ ស" ឈ្មោះ រ ស ហៅ "ខ" និងឈ្មោះ ម មធ រួមគ្នាសងសំណង និង ជំងឺចិត្តទៅអ្នកស្រី ស មឡ ជាប្រពន្ធរបស់ឈ្មោះ ម ម សរុបចំនួន ១០ម៉ឺន ដុល្លា (ដប់ម៉ឺន ដុល្លាអាមេរិកគត់) សំណើលើសពីនេះត្រូវបដិសេធចោល ។

៥- ករណីជនណារឹងរូស ត្រូវដាក់គុកបង្ខំលើរូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ តាមច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៦- <u>វត្ថុតាង</u> : ម៉ូតូសាន់យ៉ាន់មួយគ្រឿងដែលជារបស់ឈ្មោះ ខ សច ហៅ "ណា" ត្រូវប្រគល់អោយឈ្មោះ ខ សច វិញ ។

-រីឯម៉ូតូម៉ាកគ្រីសស្កាល់មួយគ្រឿង ជាមធ្យោបាយប្រព្រឹត្តបទល្មើស ត្រូវរឹបអូសទុកលក់ឡាយឡុង យកប្រាក់សងទៅដើមបណ្តឹងរដ្ឋប្បវេណី ។

៧- សាលក្រមនេះបានជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទឈ្មោះ ម មធ ឈ្មោះ ខ សច ហៅ "ណា" និងកំបាំងមុខជនជាប់ចោទឈ្មោះ ចា សរ ហៅ "ខ ស" ឈ្មោះ រ ស ហៅ "ខ" សំរេចបើកផ្លូវបណ្តឹងទាស់ និង បណ្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៩៧ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់លោកព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ស មឡ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់មេធាវី

ជ  ចធរ  ចុះថ្ងៃទី ២៣  ខែ មិថុនា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ខ  លអ. ឈ្មោះ ជ  សថ និង ឈ្មោះ ម  មធ  ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣ (ច) ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល  លើកលែងតែចំណុចទី ២ នៃសេចក្តីសំរេច ត្រូវបដិសេធចោល និង កែប្រែចំណុចទី ៤ នៃសេចក្តីសំរេចដោយអោយឈ្មោះ  ហ  សរ  ហៅ "ថ ស" រួចផុតពីការទទួលខុសត្រូវលើសំណងជម្ងឺចិត្ត ។ ចំណុចក្រៅពីនេះ តម្កល់ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ម  មធ ឈ្មោះ ជ  សថ ហៅ "ម សណ" មេធា វីរបស់ជនជាប់ចោទ ម  មធ ឈ្មោះ អ  ទជ មេធាវីការពារជនជាប់ចោទ ជ សថ ហៅ "ម សណ" និង ជនជាប់ចោទឈ្មោះ ហ សរ ហៅ "ថ ស" ឈ្មោះ ព ធគ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស  មឡ និង មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជ  ចធរ កំបាំងមុខជនជាប់ចោទ ឈ្មោះ ហ សរ  ហៅ "ថ ស" និង រ ស ហៅ "ជ" ។ បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌ លេខ ២៦០ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍សំរេច :

១-ទទួលបណ្តឹងរបស់ជនជាប់ចោទ រ  ស ហៅ "ជ" ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាលេខ ៤៧ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៣-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីជនជាប់ចោទ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៩ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០ របស់តុលាការកំពូលសំរេច :

១-ទទួលបណ្តឹងសាទុក្ខលេខ ១៧ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ របស់អ្នកស្រី ស  មឡ និង  បណ្តឹងសាទុក្ខលេខ ៣៧  ចុះថ្ងៃទី ១៨  ខែ តុលា  ឆ្នាំ ១៩៩៩  របស់ឈ្មោះ រ ស ហៅ "ជ" ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌ លេខ ៤៧  ចុះថ្ងៃទី ២៤  ខែ កុម្ភៈ  ឆ្នាំ ១៩៩៩ និង សាលដីកាព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ២៤ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០ ។



Scanned with CamScanner

- បានឃើញរបាយការណ៍ចុះថ្ងៃទី.......ខែ............ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ វ ស បានឆ្លើយថា :ខ្លួនទទួលស្គាល់ការចោទប្រកាន់រកមេធាវីអោយខ្លួន ។ ខ្លួនស្គាល់ ជ សច ដោយសារផ្ទះខ្លួននៅវត្តសន្សំកុសល ហើយធ្លាប់ស៊ីនៅជាមួយគ្នា ។ ខ្លួនបានបាញ់សម្លាប់មែនដោយឈ្មោះ ជ សច ជាអ្នកចង្អុលបង្ហាញ ។ ឈ្មោះ ម ម ខ្លួនមិនស្គាល់ទេ ។ ពេលផឹកស្រវឹង ជ សច បានប្រាប់អោយខ្លួនសំលាប់មនុស្សម្នាក់ គឺអ្នកឈរនិយាយទូរស័ព្ទឈ្មោះ ម ម ។ឈ្មោះ ជ សច ហុចកាំភ្លើង K59 អោយខ្លួនបាញ់ ម ម តែបើមិនព្រម គេគំរាមសម្លាប់ខ្លួន និង គំរាមប្រពន្ធខ្លួនទៀត ។ ក្រោយពេលសំលាប់មក ម មធ យកប្រាក់មកអោយខ្លួនចំនួន ១ 000 ដុល្លា ( មួយពាន់ដុល្លារអាមេរិកគត់ ) ។ ពេលបាញ់ពួកខ្លួនមានម៉ូតូពីរគ្រឿងសំរាប់រត់ មួយរបស់ឈ្មោះ ម មធ ម៉ាក Crystal ឯមួយទៀតរបស់ឈ្មោះ ជ សច ម៉ាក SANYANG នៅពីក្រោយ ។ មុនពេលបាញ់ខ្លួនមិនស្គាល់ជនរងគ្រោះទេ ។ ជ សច ជាអ្នកហុចកាំភ្លើងអោយខ្លួន ជ សច នៅចំងាយប្រហែល ១00 ម ពីកន្លែងកើតហេតុ ឯឈ្មោះ ចា សរ មិនស្គាល់ ក្រោយសម្លាប់ហើយ ឈ្មោះ ជ សច ជាអ្នកអោយលុយ ។ ពេលនេះខ្លួនមានការសោកស្តាយ និង ចង់កែប្រែខ្លួន ។

-ជនជាប់ចោទ ឈ្មោះ ជ សច ឆ្លើយបញ្ជាក់ថា : ពេលខ្លួនជិះម៉ូតូជិតដល់នាគបាញ់ទឹក សមត្ថកិច្ចចាប់ខ្លួន យកខ្លួនទៅវត្តភ្នំ រឺខ្លួន បានសួរខ្លួននៅក្នុងឡាន ក្រោយមកខ្លួនបានថ្កិតមេដៃនៅក្នុងកំណត់ហេតុកាលនៅប៉ូលីស ។ ចំលើយឆ្លើយនៅចៅក្រមស៊ើបអង្កេតខ្លួនបដិសេធ ខ្លួនមិនដែលស្គាល់ឈ្មោះ ម ម និង វ ស ទេ ។ ចា សរ ខ្លួនស្គាល់ ឯ វ ស មិនស្គាល់ ។ ខ្លួនមិនដឹងថ្ងៃកើតហេតុទេ ខ្លួនមិនបានយកលុយគាត់ រឺ យកកាំភ្លើងទៅឱ្យគេ ខ្លួនក៏មិនស្គាល់ឈ្មោះ ម មធ ទេ ខ្លួនសុំបដិសេធចំលើយរបស់អ្នកទាំងពីរ ។ ជ ស ខ្លួនស្គាល់ ខ្លួនបើកឡានអោយគាត់ និង ជូនកូនគាត់ទៅរៀន ខ្លួនសុំបដិសេធ ខ្លួនមិនបានបញ្ជាឱ្យគេបាញ់ទេ ។ បើខ្លួនបញ្ជាចុះហេតុអី ពេលនោះខ្លួនក៏មិនធ្វើខ្លួនឯងទៅ ។ ខ្លួនមិនបានផ្តល់កាំភ្លើង និង ទំនាក់ទំនងជាមួយ វ ស ទេ ។ ខ្លួនមិនបានចង្អុលបង្ហាញផ្ទះជនរងគ្រោះទេ ។ ជ ស ខ្លួនស្គាល់ តែ ម មធ ខ្លួនឥតស្គាល់ទេ ហើយចំលើយខ្លួនឆ្លើយនៅទីនេះជាចំលើយពិតប្រាកដ ។

- ក្រឡាបញ្ជីអានចំលើយដើមបណ្តឹងរដ្ឋប្បវេណី ស មឡ

- ក្រឡាបញ្ជីអានចំលើយ ម មធ

-តុលាការមានប្រសាសន៍ថា ឈ្មោះ ម មធ ព្រះមហាក្សត្រលើកលែងទោស ដូចនេះមិនលើកយកមកពិចារណាទេ រឿងនេះបង្វិលមកពីតុលាការកំពូល ។ តុលាការអានរបាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍ និង អានសាលដីការបស់តុលាការកំពូល ព្រមទាំងចំលើយរបស់ឈ្មោះ ជ សច ។



Scanned with CamScanner

## មេធាវីធ្វើការសន្និដ្ឋាន

- មេធាវី : ខ សន សុំបដិសេធចំលើយរបស់ រ ស សុំឱ្យតុលាការតម្កល់សាលដីការបស់សាលាឧទ្ធរណ៍លេខ ៤៧ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ទុកជាបានការពេញទាំងមូល ។

- មេធាវី : ៩ សគ ឈ្មោះ រ ស ពិតជាបានប្រព្រឹត្តអំពើល្មើសពិតប្រាកដមែន តែស្ថិតនៅក្នុងដំណាក់កាលខ្វះការពិចារណា សុំអោយតុលាការបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន សុំផ្តន្ទាទោសនៅកំរិតអប្បបរមានៃទោស ។

## តំណាងមហាអយ្យការសន្និដ្ឋាន

- ឈ្មោះ រ ស តុលាការក្រុងភ្នំពេញសំរេចត្រឹមត្រូវ ឈ្មោះ ៩ ស តុលាការសំរេចត្រឹមត្រូវ ឈ្មោះ ៩ សច មានធាតុផ្សំគ្រប់គ្រាន់ សំរេចផ្តន្ទាទោស ៩ សច តាមមាត្រា ៣៤ អំពីសំណង ដើមបណ្តឹងរដ្ឋប្បវេណីបាន ដកបណ្តឹងសុំអោយតុលាការសំរេចតាមច្បាប់ ។

## តុលាការថយពិភាក្សា

- ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទទាំងពីរឆ្លើយ
- ក្រោយពីបានស្តាប់ការអំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើឯកសារពាក់ព័ន្ធ
- ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍ភ្នំពេញ

### យល់ឃើញថា :

-ទទួលជំនុំជំរះរឿងក្តីនេះឡើងវិញ តាមអំណាចសាលដីកាតុលាការកំពូល លេខ ១៩ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០ ។

- សាលដីកាសាលាឧទ្ធរណ៍លេខ ៤៧ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ដែលបានសំរេចតម្កល់សាលក្រមតុលាការក្រុងភ្នំពេញ លេខ ១៣ ( ច ) ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៨ ទុកជាបានការហើយ តុលាការកំពូលបានសំរេចតាមដីកាលេខ ១៩ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០ ចាត់ទុកសាលដីកាសាលាឧទ្ធរណ៍ជាមោឃៈនោះ ត្រូវសាលក្រមតុលាការក្រុងក្លាយជាមោឃៈតាមគ្នា ដោយដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទបានប្តឹងឧទ្ធរណ៍ និង ប្តឹងសាទុក្ខដូចគ្នា ។ ដូចនេះគប្បីសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញទាំងអស់ ។

- ក្នុងការដេញដោល ក្នុងពេលសវនាការនេះ ឈ្មោះ រ ស បានបញ្ជាក់ថា កាលនៅចំពោះមុខសាលាឧទ្ធរណ៍នៅក្នុងសវនាការកន្លងទៅម្តងហើយនោះ ដោយមានការទុកចិត្តទៅលើគេម្នាក់ដែលមិន



Scanned with CamScanner

ស្គាល់ឈ្មោះ និង ស្គាល់ទីលំនៅរបស់គេ ម្ល៉ោះហើយខ្លួនក៏បានឆ្លើយទទួលសារភាពគ្រប់យ៉ាងថាបាន ប្រព្រឹត្តបទល្មើសសម្លាប់មនុស្សតែម្នាក់ឯង គតមានអ្នកណាចូលរួមទេ ។ ទើបពេលនេះខ្លួនដឹងថា ត្រូវ ចាញ់បោកគេ ។ តាមពិត ពិតមែនតែខ្លួនជាអ្នកសម្លាប់ផ្ទាល់ក៏ដោយ ខ្លួនក៏ស៊ីឈ្នួលគេដែរ ដែលមាន ឈ្មោះ ឌ សច ហៅ "ណ" ជាអ្នកផ្តល់អាវុធ និង បង្ហាញជនដែលត្រូវសម្លាប់ ហើយឈ្មោះ ឌ សច ហៅ "ណ" ជាឈ្មោះ ឃ សរ ហៅ "ទ ស" ជាអ្នកជួល ប៉ុន្តែខ្លួនមិនដែលជួបឈ្មោះ ឃ សរ ហៅ "ទ ស" នោះទេ ។ ការដោះសារខាងលើនេះ ដោយគ្មានភស្តុតាងអ្វីសំរាប់ដោះបន្ទុកថាត្រូវ ចាញ់បោកគេនោះ សាលាឧទ្ធរណ៍មិនអាចជឿបានឡើយ ព្រោះថាឈ្មោះ រ ស ធ្លាប់បំរើការងារជា យោធាមានការទទួលខុសត្រូវខ្ពស់ អាចនឹងដឹង.ហេតុផលល្អអាក្រក់រាល់អំពើដែលបានប្រព្រឹត្ត ។ ដូច្នេះ បង្ហាញអោយឃើញថា សាលាឧទ្ធរណ៍ ដែលបានសំរេចម្តងហើយតាមសាលដីកាលេខ ៤៧ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ នោះបានត្រឹមត្រូវ តាមលក្ខណៈច្បាប់ហើយ ។

-ការដោះសាររបស់ឈ្មោះ ឌ សច ហៅ "ណ" តាំងពីនៅចំពោះមុខតុលាការថ្នាក់ក្រោម និង ចំពោះមុខសាលាឧទ្ធរណ៍ នៅពេលមុនក៏ដូចជានៅពេលនេះដែរ បានរក្សាគោលជំហររបស់ខ្លួន ដដែល ដូចនេះបង្ហាញអោយឃើញថា សាលាឧទ្ធរណ៍ និង តុលាការក្រុងបានសំរេចរួចមកហើយនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-យោងតាមពាក្យស្នើសុំរបស់ឈ្មោះ ស មឡ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០១ ជាដើម បណ្តឹងរដ្ឋប្បវេណី បានស្នើសុំឈប់ប្តឹងទាមទារប្រាក់សោហ៊ុយបង់ខាតជំងឺចិត្តពីជនជាប់ចោទ និង ឈប់ ប្តឹងតវ៉ាទាំងអស់ ។ ការស្នើសុំនេះចំពោះបណ្តឹងរដ្ឋប្បវេណី សាលាឧទ្ធរណ៍អាចទទួលយកបាន តែចំពោះ ការផ្តន្ទាទោសជនល្មើស ច្បាប់មិនលំអានតាមពាក្យសុំនេះទេ ។

-មតិភាគច្រើន នៃក្រុមប្រឹក្សាជំនុំជំរះ យល់ថាសាលាឧទ្ធរណ៍ដែលបានសំរេចម្តងហើយនោះ មានលក្ខណៈត្រឹមត្រូវហើយ ម្យ៉ាងទៀតសាលដីកាសាលាឧទ្ធរណ៍បានសំរេចម្តងហើយនោះ លោក អគ្គព្រះរាជអាជ្ញា មិនបានប្តឹងសាទុក្ខដែរ ដែលនាំអោយសាលដីកានោះមានអានុភាពអនុវត្តបានហើយ តែដោយមានបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏មានការផ្អាកការអនុវត្តន៍សាលដីកានោះ លុះ មកពេលនេះ បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានដកបណ្តឹងរបស់ខ្លួន ម្ល៉ោះហើយអាចចាត់ទុក ថា ដើមបណ្តឹងរដ្ឋប្បវេណីសុខចិត្តទទួលយកសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍នោះហើយ ។

## <u>វិនិច្ឆ័យសេចក្តី</u>

១-សម្រេចទទួលជំនុំជំរះរឿងក្តីនេះឡើងវិញតាមអំណាចសាលដីកាលេខ ១៩ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០០ របស់តុលាការកំពូល ។

២-សម្រេចអោយឈ្មោះ ឃ សរ ហៅ "ស" និង ឈ្មោះ ឌ សច ហៅ "ណ" រួចខ្លួនពីបទ ចោទប្រកាន់ក្នុងបទសមគំនិតធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាល ពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។



Scanned with CamScanner

បង្គាប់អោយដោះលែង ឈ្មោះ ៩ សខ ហៅ "ឍន" ឱ្យមានសេរីភាពឡើងវិញ កាលបើគ្មានដីកាឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀត និង បង្គាប់អោយឈប់ស្វែងរកចាប់ខ្លួនឈ្មោះ ២ សរ ហៅ "ស" ពីបទជាប់ចោទក្នុងបទល្មើស "សមគំនិតធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ កាលបើឈ្មោះនេះគ្មានដីកាស្វែងរកចាប់ខ្លួនក្នុងបទល្មើសអ្វីផ្សេងទៀត ។

៣-សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ រ ស កំណត់ដប់ពីរឆ្នាំ " ១២ ឆ្នាំ " គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៩ ពីបទ " ធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន " ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ តាមបញ្ញត្តិមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤-សម្រេចទទួលសំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលឈប់ប្តឹងទាមទារសោហ៊ុយបង់ខាតជំងឺចិត្តពីជនជាប់ចោទ ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០១ នៅចំពោះមុខជនជាប់ចោទ និង មេធាវី កំចាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និង ឈ្មោះ ២ សរ ហៅ "ស" ប្រកាសជាសាធារណៈនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០១ ចំពោះមុខមេធាវី កំចាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| ហ គះ | សុះ សជ និង ស សះ | ប ន |

---

| | |
| --- | --- |
| បានឃើញ | បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានក្រុមប្រឹក្សាជំនុំជំរះ | ភ្នំពេញ, ថ្ងៃទី ១៤ខែ សីហា ឆ្នាំ ២០០១ |
| ហត្ថលេខា | ក្រឡាបញ្ជី |
| ប ន | ហត្ថលេខា |
| | ហ គះ |